

Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org

## 3.05 នាងរ៉ាហាប់ និងអ្នកស៊ើបការណ៍

ព្រះបានឱ្យលោកម៉ូសេដឹកនាំប្រជាជនរបស់ទ្រង់គឺជនជាតិអ៊ីស្រាអែលចេញពីស្រុកអេស៊ីបទៅកាន់ស្រុកកាណានដែលជាទឹកដីសន្យា។ នៅពេលពួកគេនៅជិតដល់ស្រុកកាណាន លោកម៉ូសេបានចាត់អ្នកស៊ើបការណ៍ចំនួន ១២ នាក់ ឲ្យទៅមើលស្រុកនោះមុន។ អ្នកស៊ើបការណ៍ពីរនាក់គឺយ៉ូស្វេ និងកាលែបបាននិយាយថាទឹកដីនោះល្អ ហើយប្រជាជនអ៊ីស្រាអែលគួរតែប្រយុទ្ធយកវា។ ពួកគេបានប្រាប់លោកម៉ូសេថា ព្រះបានសន្យានឹងពួកគេនូវទឹកដី ហើយទ្រង់នឹងជួយពួកគេឱ្យយកឈ្នះលើទឹកដីនោះ។ ប៉ុន្តែអ្នកស៊ើបការណ៍ ១០ នាក់ផ្សេងទៀតភ័យខ្លាចទៅវិញ។ ពួកគេបានបញ្ចុះបញ្ចូលប្រជាជនថា ពួកគេនឹងចាញ់បើសិនជាមានការប្រយុទ្ធគ្នា។ ប្រជាជនក៏មានការភ័យខ្លាច ពួកគេមិនទុកចិត្តព្រះថា ទ្រង់នឹងសំរេចនូវអ្វីដែលទ្រង់បានសន្យាឡើយ។ ដោយសារតែការសង្ស័យរបស់ពួកគេព្រះបានបណ្តាលឱ្យពួកគេវង្វេងនៅក្នុងវាលរហោស្ថានអស់រយៈពេលសែសិបឆ្នាំ។

ច្រើនឆ្នាំបានកន្លងផុតទៅ ប្រជាជនអ៊ីស្រាអែលបានចូលទៅជិតស្រុកកាណានម្តងទៀត។ លោកម៉ូសេមានអាយុ ១២០ ឆ្នាំ។ វាជាពេលវេលាដែលគាត់ត្រូវចែកឋានទៅហើយ។ ជនជាតិអ៊ីស្រាអែលនាំគ្នាយំសោកចំពោះលោកម៉ូសេ។ ព្រះបានមានបន្ទូលទៅកាន់យ៉ូស្វេ ហើយបានប្រាប់គាត់ឱ្យដឹកនាំប្រជាជនដែលនៅសល់ទៅទឹកដីដែលបានសន្យា។ ព្រះអម្ចាស់មានព្រះបន្ទូលថា "យើងនឹងគង់នៅជាមួយអ្នក យើងនឹងមិនចាកចេញពីអ្នកទេ យើងនឹងផ្តល់កម្លាំង និងភាពក្លាហានដល់អ្នក យើងនឹងនៅជាមួយអ្នកគ្រប់ជំហានទាំងអស់"។ ប្រជាជនបានស្តាប់បង្គាប់លោកយ៉ូស្វេដូចពួកគេបានស្តាប់បង្គាប់លោកម៉ូសេដែរ "អ្វីគ្រប់យ៉ាងដែលអ្នកបញ្ជាយើងនឹងធ្វើតាម ទីណាដែលលោកចាត់ឱ្យយើងទៅ យើងនឹងទៅ" នេះជាអ្វីដែលពួកគេប្រជាជនបាននិយាយទៅកាន់លោកយ៉ូស្វេ។

លោកយ៉ូស្វេបានចាត់អ្នកស៊ើបការណ៍ពីរនាក់ទៅក្រុងយេរីខូរនៅស្រុកកាណានដើម្បីសង្កេតមើល។ ប្រជាជននៅក្រុងយេរីខូរបានឮពីការអស្ចារ្យ ដែលព្រះបានធ្វើសម្រាប់រាស្ត្ររបស់ទ្រង់។ ពួកគេបានដឹងថា ព្រះអម្ចាស់ញែកសមុទ្រឱ្យពួកគេឆ្លងកាត់ និងរំដោះគេចេញពីស្រុកអេស៊ីប។ ពួកគេមានការភ័យខ្លាចពេលដែលគិតដល់ជនជាតិអ៊ីស្រាអែលទាំងនេះ ដែលនឹងចូលមកវាយយកក្រុងយេរីខូរ។ មានស្ត្រីម្នាក់ឈ្មោះរ៉ាហាបដែលមានផ្ទះមួយនៅក្រុងយេរីខូរ។ អ្នកស៊ើបការណ៍បានមកដល់ផ្ទះរបស់នាងដើម្បីស្នាក់នៅមួយយប់។ នោះស្តេចក្រុងយេរីខូរក៏ចាត់គេឲ្យទៅបង្គាប់រ៉ាហាបថា ចូរនាំមនុស្សដែលចូលមកស្នាក់នៅផ្ទះឯងនោះចេញមក ដ្បិតគេបានមក ដើម្បីនឹងដើរសង្កេតមើលពេញក្នុងស្រុកនេះ ។

ឥឡូវនេះរ៉ាហាបជឿថា ព្រះអម្ចាស់បានប្រគល់ទឹកដីកាណានដល់ប្រជាជនអ៊ីស្រាអែលហើយ។ នាងបានយកអ្នកស៊ើបការណ៍ទាំងពីរនាក់ហើយលាក់ខ្លួនពួកគេនៅលើដំបូលផ្ទះរបស់នាងនៅពីក្រោមចំបើង។ នាងទូលស្តេចថា៖ មានមនុស្សមកឯខ្ញុំមែន តែខ្ញុំឥតបានដឹងជាមកពីណាទេ លុះជិតដល់ពេលបិទទ្វារក្រុង កាលងងឹតហើយ នោះស្រាប់តែគេចេញបាត់ទៅ ខ្ញុំឥតបានដឹងជាគេទៅឯណាទេ ដូច្នេះចូរដេញតាមគេជាប្រញាប់ទៅ ដ្បិតមុខជានឹងតាមគេទាន់។ មនុស្សខ្លះរបស់ស្តេចបានចេញទៅតាមផ្លូវ ដើម្បីរកបុរសទាំងពីរនាក់នោះ។

រ៉ាហាបបានឡើងទៅលើដំបូលហើយជួបអ្នកស៊ើបការណ៍ទាំងពីរ នាងបានប្រាប់ពួកគេថា៖ យើងទាំងអស់គ្នាស្គាល់ព្រះរបស់អ្នក ទ្រង់ជាព្រះនៃស្ថានសួគ៌ និងជាព្រះនៃផែនដី។ ឥឡូវនេះសូមសន្យាដោយនូវព្រះនាមទ្រង់ ដោយខ្ញុំបានសង្គ្រោះអ្នក សូមលោកសង្គ្រោះគ្រួសារនាងខ្ញុំផង។ នៅពេលលោកមកវាយយកក្រុងយេរីខូរសូមជួយសង្គ្រោះយើងខ្ញុំផង។ អ្នកស៊ើបការណ៍បានប្រាប់នាងថា៖ នេះជាអ្វីដែលនាងត្រូវធ្វើ ចូរព្យួរខ្សែពណ៌ក្រហមនេះនៅខាងក្រៅបង្អួចទៅ គឺដូចជាអ្វីដែលនាងកំពុងតែប្រើ ដើម្បីជួយយើងឱ្យគេចខ្លួនបានដូច្នេះពេលយើងឃើញវាព្យួរឡើងយើងនឹងជួយសង្គ្រោះគ្រួសារអ្នកទាំងមូល។ ពួកគេក៏ត្រលប់ទៅវិញ។ ពួកគេជួបលោកយ៉ូស្វេហើយជំរាបលោកអំពីហេតុការណ៍ដែលកើតមានឡើងគេពោលថា៖ «ព្រះអម្ចាស់បានប្រគល់ស្រុកនេះទាំងមូល ឱ្យយើងហើយ គេរាល់គ្នាខ្លាចពួកយើងណាស់!« នៅពេលដែលជនជាតិអ៊ីស្រាអែលចូលមកវាយយកក្រុងយេរីខូរលោកយ៉ូស្វេបានចេញបញ្ជាដើម្បីជួយសង្គ្រោះជីវិតនាងរ៉ាហាប និងក្រុមគ្រួសាររបស់នាង ពីព្រោះនាងស្មោះត្រង់ក្នុងការជួយសង្គ្រោះបុរសជនជាតិអ៊ីស្រាអែលទាំងនោះ ។ ប៉ុន្តែនៅមានរឿងដ៏គួរឱ្យរំភើបមួយទៀត! **យ៉ូស្វេ ២**

# 3.05 នាងរ៉ាហាប់ និងអ្នកស៊ើបការណ៍ - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន
## កំណត់សំគាល់

១) បន្ទាប់ពីម៉ូសេស្លាប់ទៅព្រះបានប្រាប់យ៉ូស្វេឲ្យដឹកនាំជនជាតិអ៊ីស្រាអែលទៅកាន់ទឹកដីសន្យា។ យ៉ូស្វេបានចាត់អ្នកស៊ើបការណ៍ពីរនាក់ទៅក្រុងយេរីខូរដើម្បីមើលស្ថានភាព។

២) អ្នកស៊ើបការណ៍ទាំង២នាក់ស្នាក់នៅផ្ទះនាងរ៉ាហាប់។នាងបានលាក់ពួកគេនៅលើដំបូលផ្ទះនៅក្រោមចំបើង។ នាងរ៉ាហាបជឿថាព្រះទ្រង់ជាព្រះនៃស្ថានសួគ៌ និងផែនដី។

៣) ព្រះរាជាសួរនាងរ៉ាហាបថាតើនាងបានឃើញអ្នកស៊ើបការណ៍ទេ? ទ្រង់ដឹងទាំងអស់អំពីជនជាតិអ៊ីស្រាអែលនិងរបៀបដែលព្រះបានធ្វើការអស្ចារ្យសម្រាប់ពួកគេ។ ទ្រង់ខ្លាចអ្វីដែលនឹងត្រូវកើតឡើង។

៤) នាងរ៉ាហាប់បាននិយាយថានាងបានឃើញបុរសទាំងនោះ ប៉ុន្តែមិនដឹងថាពួកគេមកពីណាទេ ហើយថាពួកគេបានចាកចេញពីទីក្រុងរួចហើយ។

៥) នាងរ៉ាហាប់សុំអ្នកស៊ើបការណ៍ឱ្យជួយសង្គ្រោះនាង និងក្រុមគ្រួសាររបស់នាងពេលជនជាតិអ៊ីស្រាអែលចូលមកវាយយកក្រុងយេរីខូរ។ ដោយសាររ៉ាហាប់បានជួយសង្គ្រោះពួកគេអ្នកស៊ើបការណ៍បានសន្យាថាពួកគេក៏នឹងជួយសង្គ្រោះនាង និងក្រុមគ្រួសាររបស់នាងផងដែរ។

## សំណួរ

១) បន្ទាប់ពីម៉ូសេស្លាប់ទៅតើព្រះបានប្រាប់អ្នកណាឲ្យដឹកនាំជនជាតិអ៊ីស្រាអែលទៅកាន់ទឹកដីសន្យា?
២) អ្នកស៊ើបការណ៍ ២ នាក់ត្រូវបានបញ្ជូនទៅក្រុងយេរីខូរដើម្បីមើលស្ថានភាព តើពួកគេបានស្នាក់នៅជាមួយនរណា?
៣) តើនាងរ៉ាហាប់បានប្រាប់អ្វីដល់ព្រះរាជានៅពេលដែលទ្រង់សួរនាងអំពីអ្នកស៊ើបការណ៍?
៤) តើរ៉ាហាប់បានសុំអ្នកស៊ើបការណ៍ឲ្យធ្វើអ្វីពេលគេមកវាយយកក្រុងយេរីខូរ?

## ចម្លើយ

១) បន្ទាប់ពីម៉ូសេស្លាប់ទៅព្រះបានប្រាប់យ៉ូស្វេឲ្យដឹកនាំជនជាតិអ៊ីស្រាអែលទៅកាន់ទឹកដីសន្យា។
២) អ្នកស៊ើបការណ៍ទាំង ២ នាក់ស្នាក់នៅក្នុងផ្ទះរបស់ស្ត្រីម្នាក់ឈ្មោះរ៉ាហាប់។
៣) រ៉ាហាប់ប្រាប់ស្តេចថាអ្នកស៊ើបការណ៍បានស្នាក់នៅក្នុងផ្ទះរបស់នាងមែន តែពួកគេបានចាកចេញពីទីក្រុងហើយ។
៤) រ៉ាហាប់បានសុំឱ្យអ្នកស៊ើបការណ៍ជួយសង្គ្រោះនាង និងក្រុមគ្រួសារនាង។


Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org